**កិច្ចប្រជុំសាធារណៈ**

អគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ានឹងដឹកនាំកិច្ចប្រជុំជាសាធារណៈ ចាប់ពីថ្ងៃទី22 ខែមេសា ឆ្នាំ2021 នៅវេលាម៉ោង 1 រសៀល តាមរយៈកិច្ចប្រជុំតាមទូរសព្ទទៅលើសំណើសុំដាក់លក់របស់មន្ទីរពេទ្យ East Valley Glendora, LLC (ធ្វើអាជីវកម្មក្នុងនាមជាមន្ទីរពេទ្យសុខភាពអាកប្បកិរិយា Glendora Oaks ) ដោយក្រុមហ៊ុនមូលនិធិថែទាំសុខភាពបឋមទៅឲ្យCHLB, LLC ។

ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងរបស់ជំងឺ COVID-19 អភិបាល Newsom បានដាក់ឲ្យប្រើប្រាស់នូវបទបញ្ជា ប្រតិបត្តិលេខ N-33-20 ដែលប្រកាសពីការដាក់រដ្ឋកាលីហ្វ័រញ៉ាឲ្យនៅក្នុងភាពមានអាសន្ន និងបញ្ជាឲ្យបុគ្គលដែលរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ ស្ថិតនៅក្នុងផ្ទះ ឬកន្លែងដែលពួកគេស្នាក់នៅ លើកលែងតែមានការចាំបាច់ ដើម្បីរក្សាការបន្តប្រតិបត្តិការនៃវិស័យហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់សហព័ន្ធ។ អភិបាល Newsom ក៏បានដាក់ឲ្យប្រើប្រាស់នូវបទបញ្ជាប្រតិបត្តិលេខ N-25-20 និង N-29-20 ដែលផ្តល់សិទ្ធិអំណាចដល់ អគ្គរដ្ឋអាជ្ញាដើម្បីរៀបចំកិច្ចប្រជុំជាសាធារណៈតាមរយៈទូរសព្ទ ដោយមិនបានកំណត់នូវទីតាំងជាក់លាក់ ដែលសមាជិកនៃសាធារណៈជនអាចតាមដានកិច្ចប្រជុំ និងផ្តល់ជាមតិយោបល់ជាសាធារណៈ។

សាធារណៈជនអាចចូលទៅកិច្ចប្រជុំជាសាធារណៈនេះតាមរយៈទូរស័ព្ទនិងតាមប្រព័ន្ធអេឡិចត្រូនិច។ សាធារណៈជនអាចស្តាប់កិច្ចប្រជុំជាសាធារណៈ ឬ អាចជំនួសដោយការតាមដាន ស្តាប់ និងផ្តល់ជាមតិយោបល់ ដោយប្រើប្រាស់នូវមធ្យោបាយដូចបានរៀបរាប់ខាងក្រោម៖

**ការប្រកាសពីកិច្ចប្រជុំជាសាធារណៈនេះ ត្រូវបានដាក់នៅក្នុងគេហទំព័ររបស់អគ្គរដ្ឋអាជ្ញាជាមួយនឹងតំណរភ្ជាប់ និងសេចក្តីណែនាំអំពីការចូលរួមកិច្ចប្រជុំជាសាធារណៈ ដោយកម្មវិធី BlueJeans videoconference។ https://oag.ca.gov/charities/nonprofithosp.**

ក្នុងកំឡុងពេលប្រជុំ អ្នកចូលរួមទាំងអស់នឹងត្រូវបានដាក់ឲ្យបិទសម្លេង ដោយអ្នកសម្របសម្រួល។ អ្នកនឹងមិនអាចបិទ ឬ បើកសម្លេងដោយខ្លួនឯងបានទេ។

**សេចក្តីណែនាំអំពីការចូលរួមកិច្ចប្រជុំជាសាធារណៈ**

**ការប្រើកុំព្យូទ័រ តាមរយៈ Google Chrome Web Browser ឬ កម្មវិធី BlueJeans Events**

ដើម្បីផ្តល់ឲ្យអ្នកប្រើប្រាស់នូវបទពិសោធន៍ដ៏ល្អបំផុត BlueJeans សូមណែនាំឲ្យប្រើ Google Chrome web browser ឬ ទាញយក https://apps.apple.com/us/app/bluejeans-video-conferencing/id560788314 ដោយឥតគិតថ្លៃ។

វានឹងអាចអនុញ្ញាតឲ្យអ្នកចូលរួម បានតាមដាន ស្តាប់ និងផ្តល់ជាមតិយោបល់ នៅក្នុងកិច្ចប្រជុំជាសាធារណៈនេះ។ អ្នកចូលរួមអាចផ្តល់ជាមតិយោបល់តាមរយៈ ការសរសេរ ឬ និយាយផ្ទាល់មាត់ដោយប្រើប្រាស់នូវតំណរភ្ជាប់ខាងក្រោម៖
https://primetime.bluejeans.com/a2m/live-event/bwgywjck

សំណើសុំទំនាក់ទំនងដោយផ្ទាល់ ដើម្បីផ្តល់នូវមតិយោបល់ផ្ទាល់មាត់ដោយ៖

1. ជ្រើសរើសរូបសញ្ញាលើកដៃ នៅផ្នែកខាងស្តាំនៃអេក្រង់របស់អ្នក។
2. បន្ទាប់ពីទទួលបានការយល់ព្រមពីអ្នកសម្របសម្រួលហើយ ជ្រើសរើសពាក្យថា បន្ត។
3. បន្ទាប់មក អ្នកនឹងត្រូវបានបញ្ជូនឲ្យទៅចាំនៅក្នុងជួរ។

សូមរង់ចាំដើម្បីនិយាយ រហូតទាល់តែអ្នកសម្របសម្រួល អញ្ជើញអ្នកឲ្យផ្តល់មតិយោបល់របស់អ្នក។ បន្ទាប់មក អ្នកសម្របសម្រួលនឹងបើកមីក្រូហ្វូនរបស់អ្នក។ **អ្នកត្រូវតែមានមីក្រូហ្វូនដើម្បីបញ្ចេញនូវមតិយោបល់របស់អ្នក។**

**ឧបករណ៍ចល័ត**

ប្រើប្រាស់ឧបករណ៍ចល័ត ដូចជា ទូរសព្ទចល័ត ឬ tablet នឹងអនុញ្ញាតឲ្យអ្នកចូលរួម តាមដាន ស្តាប់ និងផ្តល់ជាមតិយោបល់នៅក្នុងកិច្ចប្រជុំជាសាធារណៈ ប្រសិនបើពួកគេទាញយកកម្មវិធី BlueJeans។

ប្រើនូវតំណរភ្ជាប់ខាងក្រោមដើម្បីចូលរួម ដោយប្រើប្រាស់ឧបករណ៍ចល័ត។ ជម្រើសនេះនឹងតម្រូវឲ្យអ្នកចូលរួមទាញយកកម្មវិធី BlueJeans និងអនុញ្ញាតឲ្យអ្នកចូលរួម តាមដានកិច្ចប្រជុំជាសាធារណៈ និងផ្តល់មតិយោបល់ជាសាធារណៈ។ អ្នកចូលរួមអាចផ្តល់ជាមតិយោបល់ បានដោយប្រើការសរសេរ ឬ ការនិយាយ។ ប្រសិនបើអ្នកចូលរួមមិនបានទាញយកកម្មវិធី BlueJeans ទេ អ្នកចូលរួមអាចបានត្រឹមតែ ស្តាប់ និងមិនអាច ផ្តល់ជាមតិយោបល់បានឡើយ។

ក) បើកតំណរភ្ជាប់នេះ៖ https://primetime.bluejeans.com/a2m/live-event/bwgywjck

ខ) ទាញយកកម្មវិធី ប្រសិនបើអ្នកមិនទាន់មានវា។

គ) បញ្ចូលលេខសម្គាល់របស់ព្រឹត្តិការណ៍ដើម្បីចូលរួម៖ bwgywjck

**តាមទូរសព្ទ**

ប្រើប្រាស់ទូរសព្ទនឹងអនុញ្ញាតឲ្យអ្នកចូលរួម ស្តាប់តែកិច្ចប្រជុំជាសាធារណៈ ប៉ុន្តែនឹងមិនអនុញ្ញាតឲ្យអ្នកចូលរួម តាមដានកិច្ចប្រជុំជាសាធារណៈ ឬ ផ្តល់ជាមតិយោបល់ឡើយ។

ទំនាក់ទំនងទៅលេខមួយក្នុងចំណោមលេខទូរសព្ទខាងក្រោម បន្ទាប់មកបញ្ចូលលេខកូដសម្ងាត់អ្នកចូលរួមអមដោយសញ្ញា # ដើម្បីបញ្ជាក់៖

+1 (415) 466-7000 (សហរដ្ឋអាមេរិក)
លេខកូដសម្ងាត់៖ 5245957 #

ឬ

+1 (760) 699-0393 (សហរដ្ឋអាមេរិក)
លេខកូដសម្ងាត់៖ 2983346016 #

**ជំនួយពី BlueJeans**

លេខទូរសព្ទក្នុងការបម្រើសេវាកម្មអតិថិជនរបស់ BlueJeans គឺ៖ +1 (408) 791-2830
អ្នកចូលរួមក៏អាចស្វែងរកជំនួយនៅ៖ https://support.bluejeans.com

**គោលបំណងនៃកិច្ចប្រជុំជាសារធារណៈ**

គោលបំណងនៃកិច្ចប្រជុំជាសារធាណៈនេះ គឺដើម្បីឲ្យទទួលបាននូវមតិយោបល់អំពីសំណើសុំដាក់លក់របស់មន្ទីរពេទ្យ East Valley Glendora, LLC (ធ្វើអាជីវកម្មក្នុងនាមជាមន្ទីរពេទ្យសុខភាពអាកប្បកិរិយា Glendora Oaks ) ដោយក្រុមហ៊ុនមូលនិធិថែទាំសុខភាពបឋមទៅឲ្យCHLB, LLC ។

**បុគ្គលនានាត្រូវបានលើកទឹកចិត្ត ឲ្យបង្ហាញពីទស្សនៈយល់ឃើញរបស់ពួកគេចំពោះប្រតិបត្តិការនៃសំណើសុំ ជាលាយលក្ខណ៍អក្សរ ទៅកាន់ការិយាល័យអគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ា ក្នុងទម្រង់អេឡិចត្រូនិកទៅកាន់ Lily.Weaver@doj.ca.gov ឬផ្ញើសំណៅថតចម្លងតាមប្រៃសណីយ៍ទៅកាន់ Lily Weaver អគ្គរដ្ឋអាជ្ញារង តាមរយៈអាសយដ្ឋាន 1300 I Street, Sacramento, CA 95814 ។ រយៈពេលផុតកំណត់នៃការទទួលមតិយោបល់ជាលាយលក្ខណ៍អក្សរនេះ គឺនៅថ្ងៃទី22 ខែមេសា ឆ្នាំ2021 នៅម៉ោង 5 ល្ងាច។**